ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគម្រប់បី

ខ្សែ ៤

ក្រុងភ្នំពេញ

រោងពុម្ពរាជការ គូវែរណឺម៉ង់

គ្រិ. ឆ្នាំ ១៩៣០

ពុ. ស. ២៤៧៣

អ្នកទទួលខុសត្រូវ ជុំ-មៅ

# បញ្ជីរឿង

ទំព័រ

១- អំពីព្រះពុទ្ធរូបសម្រិទ្ធ ១ អង្គ ក្រោមវិហារដែលមាននៅក្នុងព្រះរាជបណ្ណា-
ល័យ ម៉ាដឺម៉ូអាហ្វែល ស៊ុយសាន ការប៉ុវៀស អធិប្បាយ . . . ៩៣

២- ជាផ្លូវបទ ក្រុមព្រះជំរុងរាជានុភាព អំពីមូលហេតុនៃការព្រះសាសនាស្រុក-
សៀម ព្រះមហាវិទូរក្រសេមប្រែជាភាសាខ្មែរ . . . . . ៩៥

៣- មិលិន្ទបញ្ហា ព្រះគ្រូវិមលបញ្ញា អ៊ុម-ស៊ូ អាចារ្យនៅព្រះរាជបណ្ណាល័យ
កម្ពុជា ប្រែចេញពីបាលី (ត) . . . . . . .

៤- គតិលោក ឬច្បាប់ទូន្មានខ្លួន ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ រៀបរៀង (ត) .
( គតិលោក និង មិលិន្ទបញ្ហា មិនបានចុះក្នុងនេះទេ ព្រោះមានបោះ
សៀវភៅដោយឡែកហើយ ) . . . . . . .

៥- រឿងមហាភារតយុទ្ធ ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជ
បណ្ណាល័យ ប្រែពីភាសាសៀម (ត) . . . . . ១០៣

# អំពីព្រះពុទ្ធរូប ១ អង្គធ្វើដោយសម្រឹទ្ធិ
# ដែលបានមកអំពីវត្តត្របែក ខេត្តកំពង់ឆ្នាំង
## ម៉ាដឺម៉ូអាហ្សែល ស៊ុយសាន ការប៉ឺឡេស អធិប្បាយ

*ក្រុមការ ជុំ - មៅ ប្រែជាភាសាខ្មែរ*

---

## ព្រះពុទ្ធរូបគ្រាមារវិជ័យ

ព្រះពុទ្ធរូបនេះ សាងដោយសម្រឹទ្ធកំពស់ ១២ សង់ទីម៉ែត្រកន្លះ តាមពិនិត្យរូបភាពទៅឃើញថាប្រាកដជាស្នាដៃសៀម ហើយប្រហែលជាគេសាងក្នុងវេងកាលសម័យ នៃពុទ្ធសករាជពី ១៨០០ ទៅ ២០០០ ឆ្នាំ ។

ស្នាមខ្សែដែលជាប់នៅព្រះកេ្រ្គនោះរលុបខ្លះទៅហើយ នៅសល់តែផ្នត់ព្រះសុរង់ឃើញច្បាស់តាំង ៣ ជាន់ តួអង្គនិងព្រះហស្តតាំងទ្វេសក្តិសមល្អណាស់ គឺថាជាងដែលធ្វើនោះបានផ្ចិតផ្ចង់ដោយពិនិត្យពិច័យ តែជាការឥតក័ព្វណាស់ ដែលចំណែកខាងព្រះបាទមិនសក្តិសមល្មមឲ្យសរសើរបាន ដូចយ៉ាងព្រះហស្ត ។ ម្រាមមេព្រះហស្តខាងឆ្វេងទំនងជាបាក់ [illegible] ជាយូរហើយ ព្រោះស្នាមដែលបាក់នោះស្រករលោងដូចជាកន្លែងដទៃទៀត ។

ដែលមានប្រយោជន៍ជាងគេក្នុងរូបនេះ គឺបល្ល័ង្កនោះឯង ព្រោះមានរចនាជារឿងកាំស៊ីគ្នានឹងព្រះហស្តស្តាំ នៃព្រះពុទ្ធរូបនោះ ចំណាំរូប

ដែលធ្លាក់ជាប់នៅបល្ល័ង្កនោះ  យើងបានស្គាល់រូបក្រុងមារាធិរាជនៅជា កណ្ដាលហើយពលមារនៅសងខាង  ដែលឃើញមានដំបង ១ ម្នាក់នៅ ក្នុងដៃស្ដាំ  សម្ដែងអាការហាក់ដូចជាកំពុងប្រយុទ្ធ ។

តាមដែលយើងបានស្គាល់នោះ  ឃើញមានព្រះពុទ្ធរូបបែបយ៉ាង នេះ ២ អង្គទៀត  មានបល្ល័ង្កដំរេចនាទូររឿងរ៉ាវ  ដូចគ្នាដូចនេះព្រះពុទ្ធរូប ទាំង ២ អង្គនោះ  សព្វថ្ងៃនៅឯទីពិពធភណ្ឌស្ថាន  នាក្រុងបាងកក  ព្រះពុទ្ធ រូបទាំងនេះនឹងឃើញមានរូបសំណាកផ្តិតពុម្ព  ក្នុងសៀវភៅដែលព្រះរាជ បណ្ណាល័យ  កំពុងចាត់ការបោះពុម្ពដោយរួសរាន់  គឺសៀវភៅតំណាល ព្រះពុទ្ធចេតិយ៍  ដែលក្រុមព្រះដាំរុងរាជានុភាពទ្រង់ព្រះនិពន្ធ  ហើយ ដែលបានប្រែមកជាខេមរភាសា ។

ស៊ុយសាន ការប៉ុឡេស

# មូលហេតុនៃការសាសនាក្នុងប្រទេសស្យាម
# ប្រែចេញអំពីបាឋកថា របស់ក្រុមព្រះដំរុងរាជានុភាព

*ព្រះមហាពិទូរ ក្រសេម*

គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែពីភាសាសៀមមកជាភាសាខ្មែរ

---

## (១)

១. កាលខ្ញុំមកសម្ដែងបាឋកថាក្នុងសាមគ្យាចារ្យស្ថាន កាលគ្រាមុននោះ បានសម្ដែងអំពីលក្ខណៈគ្រប់គ្រងប្រទេសស្យាមក្នុងសម័យបុរាណ បាឋកថានោះ ខាងចុងពោលដល់ការគ្រប់គ្រងគណៈសង្ឃ ខ្ញុំគិតចង់នឹងសម្ដែងហូតដល់វត្តផង តែពាស់ក្នុងវេលានោះខ្ញុំគិតមិនទាន់ស្រួលក្នុងចិត្ត ដោយមានសេចក្ដីសង្ស័យក្នុងមូលហេតុនៃការស្អាងវត្ត ខ្លះមិនច្បាស់ គិតប្រាកដផ្លូវអធិប្បាយមិនទាន់ឃើញ ទើបបង្អង់ទុកត្រឹមនោះសិន លុះដល់ខែប្រាំងកាលចុងឆ្នាំនេះ ខ្ញុំបានឱកាសឡើងទៅដល់មឿងសួគិ លោកមឿងសុខោទ័យម្ដងទៀត គប់ជាគ្រាទី ៣ ទៅ គ្រានេះទទួលទីងគេកាប់ឆ្ការជម្រះទីបុរាណស្ថានរល ក្នុងកាលដែលរៀបទទួលព្រះករុណា ៗ អាចនឹងដើរចូលទៅពិចារណាមើលបានច្បាស់លាស់ជាងទៅគ្រាមុន ៗ ជាហេតុឲ្យខ្ញុំចូលចិត្តចេះដឹងឡើងក្នុងខដែលសង្ស័យអំពីមុន ល្មមនឹងនាំមកប្រកបអធិប្បាយមូលហេតុនៃការស្អាងវត្ត ក្នុងប្រទេស

ស្យាមបានហេតុ រឿងគិតថានឹងតែងសេចក្ដីសម្ដែងរឿងនេះស្នើដល់ពួកអ្នករៀនបុរាណគតិផងគ្នា ក៏ទទួលព្រះអង្គម្ចាស់ជាទីនិវត្តិស្ដេចមកបបួលខ្ញុំឲ្យទៅសម្ដែងបាឋកថា នៅទីសាមគ្គាពាក្យក្នុងឆ្នាំនេះទៀត ក៏ឃើញថាជាឱកាសដ៏សមគួរ ទើបបាននាំរឿងស្ពានវត្តក្នុងប្រទេសស្យាមមកសម្ដែងជាបាឋកថា ឲ្យលោកអ្នកទាំងឡាយស្ដាប់ក្នុងថ្ងៃនេះ ។

២. តាមតំណាលរឿងព្រះពុទ្ធសាសនាក្នុងសម័យពុទ្ធកាល កាលសម្ដេចព្រះបរមសាស្ដាស.ក្យមុនី ប្រកាសព្រះពុទ្ធសាសនានិងទ្រង់ប្រដៅវេនេយ្យសត្វក្នុងមជ្ឈិមប្រទេសនោះ អ្នកដែលកាន់ព្រះពុទ្ធសាសនា រាប់អានវត្ថុទាំង ៣ ជាគោលនាទីរបស់ព្រះពុទ្ធសាសនាហៅថា សរណៈ គឺព្រះពុទ្ធ ១ ព្រះធម៌ ១ ព្រះសង្ឃ ១ ព្រោះវត្ថុទាំង ៣ ប្រកបផងគ្នា បើខាតខានតែយ៉ាងឯណាមួយក៏មិនកើតមានជាព្រះពុទ្ធសាសនាបាន ព្រះពុទ្ធអង្គជាអ្នកត្រាស់ដឹងនូវព្រះធម៌ហើយនាំមកប្រដៅមនុស្សទាំងឡាយ បើគ្មានព្រះពុទ្ធ ក៏គ្មានអ្នកណានឹងដឹងស្គាល់ព្រះធម៌ ឬយ៉ាងក្នុងបច្ចុប្បន្ននេះ បើនាំគ្នាបំភ្លេចព្រះពុទ្ធចោលទាំងអស់គ្នា ព្រះធម៌ក៏នឹងធ្លាក់ទៅជាអាបមិនជាសាសន៍ បើប្រសិនជាគ្មានព្រះធម៌ ព្រះពុទ្ធក៏មិនអាចនឹងមានឡើងបាន ឬយ៉ាងក្នុងបច្ចុប្បន្ននេះ បើនាំគ្នាបំភ្លេចចោលព្រះធម៌ទាំងអស់គ្នា ពុទ្ធចេតិយ៍ទាំងឡាយក៏នឹងក្លាយទៅជាខ្ទមអ្នកតា ចំណែកឯព្រះសង្ឃនឹងឃើញខុសគ្នាអ្វីពីបុគ្គលធម្មតា តែត្រឹមស្លៀកដណ្ដប់សម្ពត់លឿង គ្មាន

សាសនាសម្រាប់ខ្លួន បើជាគ្មានព្រះសង្ឃវិញព្រះអង្គត្រាស់ដឹងព្រះធម៌ឡើងក៏បានប្រយោជន៍ចំពោះតែព្រះអង្គ មិនអាចនឹងប្រកាសតាំងសាសនាឲ្យជា សាធារណប្រយោជន៍ ដល់ពពួកសត្វទាំងឡាយ ឬយ៉ាងសព្វថ្ងៃនេះ បើគ្មានព្រះសង្ឃរក្សាព្រះសាសនាតៗ មកហើយ ពួកយើងរាល់គ្នាក៏គ្មានអ្នកណាដឹងស្គាល់ព្រះពុទ្ធសាសនាជាដូចម្ដេច វត្ថុទាំង ៣ អាស្រ័យគ្នានឹងគ្នា ដូចពោលមកទើបហៅរួមគ្នាថា ព្រះត្រៃសារណគមន៍ ប្រែថា វត្ថុដែលគួរពឹងដល់ ៣ យ៉ាង ឬហៅមួយយ៉ាងទៀតថា ព្រះរតនត្រ័យ ប្រែថា ដួងកែវទាំងបី ព្រោះជាប់ទាក់ទងគ្នាដូចអធិប្បាយមកហើយ ។

៣. ក៏តែវត្ថុទាំង ៣ នោះមានភាពខុសគ្នា គឺព្រះពុទ្ធអង្គកាលស្ដេចរំលត់ខន្ធបរិនិព្វានហើយគ្មានបុគ្គលដទៃជាអ្នកជំនួសព្រះអង្គបាន ព្រះធម៌នោះសោត បើគ្មានអ្នកសិក្សាចងចាំទុកមកបានក៏អន្តរធានបាត់បង់ទៅ ចំណែកឯព្រះសង្ឃនោះគង់នៅបាន ដោយមានអ្នកបួសតៗ សមណវង្សរៀងមក ព្រោះសភាពផ្សេងគ្នាដូចពោលមកនេះ កាលព្រះពុទ្ធអង្គបរិនិព្វានទៅហើយ ទើបកើតមានចេតិយវត្ថុក្នុងព្រះពុទ្ធសាសនាសម្រាប់សក្ការបូជាជំនួសអង្គព្រះសម្មាសម្ពុទ្ធ ពុទ្ធចេតិយដោយកំណត់មានច្រើនយ៉ាង តែទីនេះពោលតែដែលជាតួមូលហេតុនៃការស្អាងវត្ត គឺតាមប្រវេណីដ៏មានមកក្នុងឥណ្ឌាតាំងពីមុនពុទ្ធកាល បើអ្នកទ្រង់នូវគុណ

ធម្មិកដ៏សាបនាដល់នូវមរណភាព កាលឈាបនកិច្ចសព្វហើយ គេក៏
រើសអដ្ឋិធាតុបញ្ចុះទុកក្នុងស្តូប ដែលយើងចំណាំតែហៅថាចេតិយ៍ សាង
ឡើងតាមកម្លាំងរបស់អ្នកម្ចាស់ការ មានតាំងពីថាគំនរដីឡើង ទៅដល់
សាងជារបស់ខ្ជាប់ខ្ជួនវិចិត្របញ្ចង់ កាលព្រះពុទ្ធអង្គបរិនិព្វានគេបានថ្វាយ
ព្រះភ្លើងព្រះពុទ្ធសរីរៈហើយ ក្សត្រិយ៍និងព្រាហ្មណ៍ជាម្ចាស់នគរផ្សេង ៗ
ដែលធ្លាប់គាប់អានព្រះពុទ្ធអង្គ ក៏សូមចំណែកព្រះបរមធាតុទៅ សាងព្រះ
ស្តូបបញ្ចុះទុក ឲ្យមហាជនក្នុងប្រទេសរបស់ខ្លួនសក្ការបូជា ៨ អន្លើផង
គ្នា លុះតមកក្នុងរជ្ជកាលព្រះចៅអសោកមានព្រះតេជានុភាពបានជាព្រះ
ចៅកជាធិរាជ ស្ដេចធំចម្បងស្ដេចទ្រង់ជ្រះថ្លាទំនុកបំរុងព្រះពុទ្ធសាសនា
ឲ្យរុងរឿងផ្សាយទៅក្នុងដែនដីឥណ្ឌារហូតដល់នានា ប្រទេស គ្រានោះ
ព្រះចៅអសោកមហារាជ ឲ្យប្រមូលរួបរួមព្រះបរមធាតុដែលគេបញ្ចុះទុក
ក្នុងនគរផ្សេង ៗ អំពីមុនមក បែកជាចំណែកបន្តិច ៗ ប្រទានទៅឲ្យ
សាងព្រះស្តូបបញ្ចុះទុកជាទីសក្ការបូជា តាមបណ្ដាស្រុកទេសដែលគាប់
អានព្រះពុទ្ធសាសនាផងគ្នា ក្នុងតំណាលពេលថាដល់ទៅ ៨៤.០០០
កន្លែង ខនេះគួរសន្និដ្ឋានថា តែច្រើនកប់មិនគ្រប់ជាប៉ុន្មានកន្លែង នឹង
គប្បីសន្និដ្ឋានទៅថា កាលកើតមានព្រះចេតិយ៍ដែលប្រតិស្ឋានព្រះបរម
ធាតុនៃព្រះសម្មាសម្ពុទ្ធ សឹងគេសាងឡើងនៅទីកន្លែងនោះពួកពុទ្ធសាស-
និកជនរមែងប្រជុំគ្នាទៅធ្វើសក្ការបូជា ហើយនិងជួយគ្នាបីបាច់រក្សាឲ្យ

បិតថេរជានិច្ចតមក មានទាំងអ្នកជ្រះថ្លាសទ្ធាកសាងគ្រឿងឧបករណ៍ ផ្សេង ៗ ថែមធួនឡើងតាមកម្លាំងរបស់ប្រជុំជនក្នុងទីនោះ នោះទើបកើត មានវត្តឡើងក្នុងទីផ្សេង ៗ វត្តជាន់ចាស់បំផុតដែលប្រាកដក្នុងប្រទេស សៀមនេះ គឺព្រះបឋមចេតិយ៍កកើតមានឡើង ដោយបរិយាយយ៉ាង សម្ដែងមក ។

ចំណែកឯប្រវត្តិនៃព្រះធម៌នោះ កាលព្រះពុទ្ធអង្គបរិនិព្វានហើយ ព្រះសង្ឃពុទ្ធសាវកលោកធំ ៗ បានបបួលគ្នាប្រជុំធ្វើការសង្គាយនារួបរួម ជាតក្រងព្រះវិន័យនិងព្រះធម៌ ដែលសម្ដេចព្រះបរមសាស្ដាទ្រង់បញ្ញត្តិ ប្រដៅទុកមក នាំគ្នារៀនសូត្រទន្ទេញចាំមាត់ស្ទាត់រៀងខ្លួន ហើយប្រដៅ សិស្សគណឲ្យរៀនសូត្រតគ្នាមក ក៏តែការរក្សាព្រះធម៌នោះក្នុងជាន់ដើម ប្រើវិធីទន្ទេញចាំមាត់ មិនបានកត់ទុកជាតួអក្សរ លោកដែល ជាពុទ្ធសាវក ដែលធ្លាប់បានស្ដាប់ព្រះពុទ្ធអង្គទ្រង់ប្រដៅ រមែងចូលចិត្ត សេចក្ដីក្នុងព្រះបរមពុទ្ធាធិប្បាយ បានការទន្ទេញចាំ និង ស្វាធ្យាយព្រះធម៌ វិន័យ ក៏គ្រាន់តែដូចយ៉ាងឲ្យចាំបទមាតិកា គឺម ៗ ប៉ុណ្ណេះមិនឲ្យភ្លេច លុះចំណេរកាលយូរមកតពីលោកធំ ៗ ដែលជាពុទ្ធសាវកទៅ ព្រះសង្ឃ ជាន់សិស្សានុសិស្ស បានជាគណាចារ្យ បង្ហាត់បង្រៀន តមកជាច្រើន តំណពុគ្គល សេចក្ដីចូលចិត្តក្នុងសេចក្ដីអធិប្បាយធម៌វិន័យ ក៏កើតបែប បែកផ្សេងគ្នា លោកបានប្រជុំសង្ឃធ្វើសង្គាយនា ១ គ្រាទៀត សេចក្ដី

ឃើញក៏មិនត្រឡប់ព្រមព្រៀងគ្នាវិញបាន ព្រះសង្ឃក្នុងឥណ្ឌាទើបកើតកាន់គតិផ្សេងគ្នាជា ២ ពួកគតិ ១ នោះមាននាមថា ថេរវាទ គឺកាន់លទ្ធិតាមតែដែលជឿថា ព្រះថេរជាពុទ្ធសាវកបានធ្វើសង្គាយនា កាលគ្រាដំបូងមិនព្រមកាន់យកតាមអធិប្បាយ របស់គណាចារ្យក្នុងជាន់ក្រោយ គតិរបស់ពួក ១ ទៀត មាននាមថា អាចារិយវាទ គឺកាន់តាំងលទ្ធិដើមតាំងលទ្ធិអធិប្បាយរបស់អាចារ្យ ត្បិតព្រះសង្ឃដំពូកក្រោយមានច្រើនគណៈចំនួនច្រើនជាងពួកមុន ទើបបាននាមថា មហាសំឃិក ។

ម្យ៉ាងទៀតកាលព្រះបាទធម្មាសោកមហារាជ ទ្រង់ឧបត្ថម្ភព្រះពុទ្ធសាសនានោះ ទ្រង់ជ្រះថ្លាទឹងព្រះសង្ឃពួកដែលកាន់លទ្ធិថេរវាទ មានព្រះរាជប្រាថ្នាទឹងកំចាត់ពួកកាន់លទ្ធិ អាចារិយវាទចេញ តែកំចាត់ចេញមិនបានអស់ព្រោះមានច្រើនណាស់ ព្រះបាទធម្មាសោកមហារាជ ទើបប្រជុំសង្ឃធ្វើសង្គាយនាធម៌វិន័យតាមលទ្ធិថេរវាទ ១ គ្រាទៀត រាប់ជាគ្រាទី ៣ ដែលព្រះសង្ឃរៀនសូត្រចងចាំទុកក្នុងភាសាបាលី លុះកន្លងរជ្ជសម័យរបស់ព្រះចៅអសោកមហារាជមកប្រមាណ ៦០០ឆ្នាំ មានព្រះមហាក្សត្រិយគ្រប់គ្រងគន្ធាររដ្ឋខាងប៉ែកលើនៃប្រទេសឥណ្ឌា ទ្រង់ព្រះនាម កនិស្ក បានជាព្រះចៅរាជាធិរាជ ហើយទ្រង់ទំនុកបម្រុងព្រះពុទ្ធសាសនាប្រហែលនឹងព្រះចៅអសោកមហារាជ តែទ្រង់ជ្រះថ្លានឹងព្រះសង្ឃដែលកាន់លទ្ធិអាចារិយវាទ ត្រាស់ឲ្យប្រជុំសង្ឃធ្វើសង្គាយនា១គ្រាទៀត ហើយឲ្យ

ប្តូរព្រះធម៌វិន័យអំពីភាសាបាលីជាភាសាសំស្ក្រឹតផង ការកាន់ព្រះពុទ្ធសាសនាក្នុងឥណ្ឌា ទើបញែកបែកគ្នាជា ២ លទ្ធិដាច់ខាតតាំងអំពីនោះមក លទ្ធិដែលកើតឡើងខាងប៉ែកលើមាននាមថា មហាយាន កាន់តាមគតិអាចរិយវាទ នឹងកាន់កាប់រក្សាព្រះធម៌វិន័យទុកជាភាសាសំស្ក្រឹតលទ្ធិដើមដែលកើតឡើងខាងប៉ែកក្រោមមាននាមថា សាវកយាន ឬ ហីនយាន កាន់លទ្ធិតាមបែបយ៉ាងគ្រាព្រះចៅអសោកមហារាជ នឹងគង់រក្សាព្រះធម៌វិន័យមកជាភាសាបាលីដដែល ។ លុះតមកព្រះសង្ឃទាំង ២ ពួក ក៏ចារព្រះធម៌វិន័យដាក់ជាតួអក្សរ ចែកជា ៣ បិដក គឺព្រះវិន័យ ព្រះសូត្រ និងព្រះបរមត្ថ ហៅរួមគ្នាថា ព្រះត្រៃបិដក ព្រះត្រៃបិដកនោះមានទាំងជាភាសាសំស្ក្រឹតទាំងភាសាបាលីតមក ។

(នៅមានត)

# រឿងមហាភារតយុទ្ធ

ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យកម្ពុជា

## ប្រែពីភាសាសៀម

## (គ)

---

## ភាគ ៨

## ព្រះចៅក្រុងវិរាដ

គ្រាមួយនោះ ព្រះចៅក្រុងវិរាដប្រថាប់លើរាជាសនៈ ក្នុងព្រះទីនាំងវិនិច្ឆ័យ មានអមាត្យមុខមន្ត្រីបង្គំគាល់ត្រៀបត្រា ទ្រង់ស្ដាប់ដីកា និងពាក្យស្រែកថ្លែងទុក្ខរបស់បណ្ដារាស្ត្រ កំពុងទ្រង់វិនិច្ឆ័យសេចក្ដីឲ្យទៅតាមយុត្តិធម៌ ដល់ពួកដែលត្រូវបៀតបៀន ខណៈនោះទតព្រះនេត្រទៅឃើញប្រុសបួនប្រាំនាក់តែងកាយ យ៉ាងគ្រាំគ្រាឈរនៅទ្វារព្រះបរមរាជវាំង ទើបមានព្រះរាជឱង្ការ ឲ្យរាជភក្ដីម្នាក់ទៅសួរថា អ្នកអម្បាលនោះជាអ្នកណាត្រូវការអ្វី កាលបានទ្រង់ព្រះសណ្ដាប់សេចក្ដីនោះហើយ ត្រាស់ឲ្យហៅចូលមកមុខព្រះទីនាំង ព្រះរាជទានឱកាសឲ្យគេក្រាបទូលសេចក្ដីដល់ព្រះអង្គដោយត្រង់ គ្រានោះមួយអង្គក្នុងពួកបងប្អូនទាំងប្រាំក្រាបទូលថា គ្រោះអាក្រក់មុខគួរស្ញែងដែលបានឧប្បត្តិដល់មហារាជយុធិស្ឋិរ ប្រហែលជា បានជ្រាបដល់ព្រះអង្គហើយ ហើយគ្រោះពួកទូលព្រះបង្គំជាខ្ញុំនេះ ជាភាគ

មួយក្នុងព្រះគ្រោះនោះដែរ  គឺពួកទូលព្រះបង្គំជាខ្ញុំ  ជាខ្ញុំរាជការមហារាជយុធិស្ឋិរកាលព្រះអង្គត្រូវនិរទេសចេញចាកព្រះនគរហើយ  ពួកទូលព្រះបង្គំក៏រង្គាក្នុងចិត្ត  ដោយហេតុគ្មានទីពឹង  ទើបត្រាច់ស្វែងរកទៅហ្វាយនាយដ៏សមគួរជាទីពឹងតទៅ  បានឮព្រះកិត្តិគុណរបស់ព្រះអង្គដែលទ្រង់អើពើណាស់នោះ  ទៅដឹកពួកទូលព្រះបង្គំឲ្យមកដល់ទីនេះ ពួកទូលព្រះបង្គំមានបំណងនឹងមករកការធ្វើក្នុងព្រះរាជសំណាក់ឯណាទីមួយ  តែគ្មានព្រះរាជាអង្គណាទទួលបំរើម  ចេះតែបដិសេធរាល់នគរ  ក្នុងទីបំផុតទើបមកដល់ទីនេះ  ពួកទូលព្រះបង្គំសូមប្រគល់កាយហ្វាយជីវិតនឹងព្រះអង្គ សូមជ្រកកោនក្រោមម្លប់ពោធិសម្ភារ ។

ព្រះរាជាបានទ្រង់ព្រះសណ្តាប់ហើយ  ក៏ស្លុតព្រះហឫទ័យពន់ប្រមាណ បែរព្រះភក្ត្រទៅខាងសេនាបតីមានព្រះរាជតម្រាស់ថា ការនិរទេសយុធិស្ឋិរដោយផ្លូវអយុត្តិធម៌នេះ  ធ្វើឲ្យយើងជារាជសម្ពន្ធមិត្រកើតទោមនស្សច្រើន  ហើយធ្វើឲ្យបណ្តាក្សត្រពាសពេញទាំងផែនដីបានសេចក្តីព្រួយលំបាកច្រើន  ក្សត្រមានចំនួនជាច្រើនពាន់  នាំគ្នាក្រឡុកប៉ុកប៉ាកព្រាត់ចាកទីលំនៅ  អាស្រ័យហេតុម្ចាស់ម្នាយរបស់គេត្រូវនិរទេសទៅដើរព្រៃ  សេចក្តីកំរបស់ទុរយោធន៍នេះនឹងនាំសេចក្តីវិនាសដល់ខ្លួន  យើងនឹងបដិសេធពាក្យសុំនេះមិនបាន  គេមិនបានមកសុំទាន  គេសុខចិត្តមករកការធ្វើ  ខនេះសម្តែងឲ្យឃើញច្បាស់ថា  គេមិនមែនជាយាចកដើរ

សូមទានតាមថ្នល់ គាត់ចូលទទួលគេទុកសម្រាប់គាល់បម្រើយើង ។

បាណ្ឌវក្សត្រិយ៍ក៏ព្រមគ្នាធ្វើវន្ទាព្រះរាជា ហើយក៏ថយចេញមកអំពីមុខព្រះទីនាំង តអំពីនោះមកមួយស្របក់ មានស្ត្រីម្នាក់តែងកាយរយីករបោក ដើរចូលទៅក្នុងអន្តេបុរស្ថានគឺព្រះរាជវាំងជាន់ក្នុង តែទម្រង់ឆោមល្អឥតខ្ចោះ អ្នកណាឃើញហើយក៏មានចិត្តបដិព័ទ្ធទីងឆោមរបស់នាងស្ទើរភាំងភ្លើស្មារតី ។

ព្រះរាជិនីព្រះទៅវិករាជត្រាស់សួរ នាងជាអ្នកណា នាងត្រូវការអ្វី ។

ខ្ញុំម្ចាស់ជាស្ត្រីកំសត់ឥតទីពឹង មានតែសេចក្តីព្រួយប្រាណស្ទើរប្រេះទ្រូងស្លាប់ ។

នាងឈ្មោះអី ?

នាងក្រាបទូលដោយសម្លេងស្រាលៗ ថា : សៃរិន្ធី ។

មើលទៅព្រះភក្ត្រកានី (១) បណ្តាលឲ្យឃើញថា ទ្រង់មេត្តាប្រណីដល់នាងជាប្រាកដ សេចក្តីល្អរូបល្អឆោមរបស់នាងយ៉ាងត្រចះត្រចង់ កិរិយាមារយាទដ៏រៀបរយឥតឆ្គង សមជាអ្នកមានត្រកូលឧត្តមពង្ស តែមើលទៅថែបជាមនុស្សកើតទុក្ខ មុខស្លុកមើលទៅលក្ខណៈល្អស្ទាវ ធ្វើឲ្យរានីទឹកឆ្ងល់ ទើបត្រាស់សួរថា រូបកាយរបស់នាងម៉្លេះ ម្តេចក៏មិនកំចាត់ឧបទ្រពភ័យឲ្យឃ្លាឃ្លាតចេញទៅ ។

---

១- រានី គឺព្រះរាជិនី ។

ព្រះម្ចាស់ ព្រះនាងទ្រៅបទីទ្រង់នៅរូបសម្បត្តិយ៉ាងឆើតរកទីប្រៀបបានដោយក្រ ម្តេចទ្រង់គង់ត្រូវគ្រោះកម្ម នាំឲ្យស្តេចទទួលឧបទ្-វអន្តរាយ គោរស្តេចព្រាត់ព្រាកចាកព្រះនគរ ទីងសព៌ជសម្បត្តិបាន កាលនាំមកធៀបនឹងរូបខ្ញុំម្ចាស់ ដែលគ្រាន់តែជាទាសីរបស់ព្រះទេវីសោត ក៏គោងមិនសង្ស័យក្នុងរឿងនេះ ។

ពនីត្រាស់សួរតទៅទៀតថា នាងត្រូវការអ្វី ហើយនាងក្រាបទូលទៅពីថា ខ្ញុំម្ចាស់ត្រូវការមករកការងារណាមួយធ្វើគ្រាន់នឹងបានចិញ្ចឹមជីវិត ។

នាងសុខចិត្តនៅបម្រើយើងឬ ។

សៃរិន្ធីទទួលធ្វើនាទីនោះដោយតុណ្ហីភាព ហើយថ្វាយបង្គំលាថយចេញទៅនៅក្នុងបន្ទប់ពួកសាវ៉ឡិក ( ពួកខ្ញុំពជការស្ត្រី ) ។

មុននេះយើងនឹងបានឃើញបន្ទប់ទបន្ទំរបស់ពនី វេលារាត្រីយាមយប់សន្ធ្យា ក្នុងបន្ទប់ព្រះទេវីអុជប្រទីបភ្លឺលាក្លឺព្រោងព្រាយ ពិដោ ឈ្ងុយឈ្ងប់សព្វសាយទៅដោយក្លិនប្រេងក្រអូបដែលអុជនោះ ទូទាំងល្វែងព្រះមន្ទីរ ជញ្ជាំងបន្ទប់ព្រះដំណាក់ធ្វើដោយម៉ោក សិលាឡាយថ្វីដៃជាងធ្វើដ៏វិចិត្រយ៉ាងឯក ឆ្លាក់ក្នុងសសស្ទើរលង់លើងព្រិលនេត្រ ព្យួររំយោលរយ៉ាដែលថ្វីដៃបាក់ជារូបផលាផល នឹងទង់ក្រស់រើក មុខគួរមើលត្រកាលក្នែក នឹងតាំងគ្រឿងតាំងដ៏មានតម្លៃឯទៀតជាច្រើន ទីផ្ទៃ

ព្រះតំណាក់ក្រាលដោយសិលាទន់ ហើយក្រាលព្រំចៀមដ៏ទន់ត្រជាក់ ជើងមានជាយប៉ាក់តាក់ចំដោយខ្សែរសយមាសប្រាក់ មានព្រះខែនក្ចុកដ៏ ចិញ្ចូងជាសសំពត់ព្រែ តាំងនៅកណ្តាលបន្ទប់នេះ សៃរិន្ទ្រីតែងចូល គាល់បម្រើព្រះទេវីដល់ក្នុងបន្ទប់នេះ ។

ក្នុងបន្ទប់១ទៀតមានបៀបប្រហែលគ្នានេះ គិច្ចកលព្រះអនុជរបស់ ពនី កំពុងផ្ទុំក្រៀមក្រំដាលដំក្នុងឧកជាទម្ងន់ ជួនកាលក៏ថ្ងូររវើរវាយ ជួនកាលក៏ដកដង្ហើមធំយូ ព្រះជេដ្ឋកតិនី ពនីព្រះពៅវិកជ ប្រថាប់ទៀបព្រះខែនក្ចុក យកព្រះហស្តស្ទាបព្រះនលាតអនុជ ដើម្បីនឹងរម្ងាប់សេចក្តីឈឺចាប់ឲ្យធូរស្បើយទៅ តែក៏មិនស្បើយស្ហើយទៅបានដូចនឹក លំដាប់នោះព្រះអនុជទ្រង់ព្រះកន្សែងគក់ទូលហើយមានបន្ទូលចេញមកថា ម្ចាស់បងប្រហែលជាពោលប្អូនឲ្យស្លាប់ចង់តែឯងហើយ ឬ ?

មិនមែន ៗ ទេ បងមិននិយាយនឹងប្អូនឯងហើយ បើឯងនិយាយព្រើល ៗ ដូចនេះ អ្វីមកបញ្ចោលចិត្តឲ្យនឹកដល់មច្ចុរាជ ប្អូនឯងប្រឈួនបន្តិចបន្តួចប៉ុណ្ណោះតើ មិនប៉ុន្មានថ្ងៃក៏ជា ជាប្រក្រតីទៅវិញ ។

កុំគប្បីនឹកដូចនោះឡើយម្ចាស់បង ការរោគប្អូនគ្រានេះមិនមែនតិចតួចយ៉ាងម្ចាស់បងសម្គាល់ សមុដ្ឋានរោគនៅក្នុងចិត្ត ហើយដែលនឹងបាត់ទៅបាន ដោយហេតុពីរយ៉ាង ឯណានីមួយ គឺស្លាប់បង់ឬ ។

កទីត្រាស់កាត់សំនួនពាក់កណ្ដាលឡើងថាទៀតហើយ ។ ប្អូនឯងនិយាយចេញឈ្មោះសេចក្ដីស្លាប់ទៀតហើយ បងមិនចង់ស្ដាប់ពាក្យប្អូនឯងហើយ ។

ល្អហើយ ថាបើដូចនោះ ទូលបង្គំគោងធ្វើមុខក្រាស់លមើល បើម្ចាស់បងប្រទានអភ័យរឿងមុខក្រាស់ ទូលបង្គំនឹងទូលរឿងពិតហើយ នឹងបញ្ចេញសេចក្ដីស្ងាត់កំបាំង នៃអាការកេតក្នុងខ្លួនឲ្យទ្រង់ជ្រាប ។

សេចក្ដីស្ងាត់កំបាំងអីប្រុសអើយ ?

ម្ចាស់បងប្រទានទោសឲ្យទូលបង្គំ ឬ ?

កទីនឹកឆ្ងល់ មិនដឹងបើនឹងមានសរនិយថាដូចម្ដេច ។

ព្រះនាងចូលព្រះហឫទ័យថា ចិត្តអនុជវវេទៅដោយសេចក្ដីឈឺចាប់ មានសតិវិប្បលាសនិយាយរវើរវាយទៅ ព្រះនាងទ្រង់សន្និដ្ឋានថា សម្ផ្ដានអាការប្រឈួននៃព្រះអនុជគង់មកពីសេចក្ដីញើករញ្ញុក ឬសេចក្ដីខឹងអើរអ៊ូ សូម្បីតែបន្តិចបន្តួចក៏ដរទៅជាធំខ្លាំងឡើងបាន អាចធ្វើឲ្យអ្នកជម្ងឺមានអាការធ្ងន់ពៀបទៅបានព្រះនាងទ្រង់ចិន្ដាថា គួរល្បួងលោមសួរយកសេចក្ដីអំពីអនុជរឿងដែលអនុជនឹងកំដាយចេញមកនោះ ជាមានសារៈឬគ្មានសារៈដូចម្ដេចក៏តាមការ ការដែលល្បួងលោមសួរយកសេចក្ដីពិត ដូចនេះ គង់ជាមិនពាស់ខុសអ្វី ព្រះនាងទើបត្រាស់ល្បួងលោមដោយព្រះសូរ

សៀងជីផ្អែមល្ហែមថា : កិច្ចក ! បាឯងឈឺប្អួនសម្លាញ់បង ចូរប្រាប់បង ឲ្យសព្វគ្រប់មកមើល ។

កិច្ចក ក៏បញ្ចេញសេចក្តីស្ទាត់កំបាំងក្នុងចិត្ត ថ្វាយព្រះនាង បង ទ្រង់ព្រះសណ្តាប់ដោយឥតខ្លាសថា ឆោមល្អនៃនាងសែនរិទ្ធីសារទៀត ស្តេចបង បានចូលមកសន្ធិតក្នុងចិត្តទូលបង្គំតាំងថ្ងៃតាំងយប់ ការដែលនាង ប្រើចុងក្អែកក្រឡេកម្តង ៗ ធ្វើឲ្យទូលបង្គំតាប់ចិត្តបដិព័ទ្ធមិនភ្លេច ១ វេលា តាំងអំពីខណៈដែលបានឃើញកែវក្រ្ពរបស់នាងមកទើសនឹងវេលា នេះ ទូលបង្គំពេញទៅដោយសេចក្តីទុក្ខក្តុកក្តួលអួលក្នុងឧក ដោយហេតុ ត្រូវកាមសរ ( សរ គឺកាម ) របស់នាង ។

ទូលប៉ុណ្ណោះហើយ ក៏បណ្តាលអាក់អួលឈ្លលឡើង ទឹកព្រះនេត្រ ស្រក់ផ្តុក ៗ កាទី ឃើញព្រះអនុជកន្ទេង ក៏ចូលព្រះហឫទ័យថា នេះ ព្រោះសេចក្តីស្រឡាញ់ មកគ្របប្រតដួងចិត្តអនុជ ព្រះនាងក៏ទ្រង់ ជាស់តឿនអនុជ ក្នុងរឿងដែលចង់ចិត្តស្រឡាញ់ ដ៏មិនគប្បី ជា ហេតុនាំមកនៅសេចក្តីអប្បយសថា : បាឯង មិនទឹកដល់សេចក្តីថោក ទាបកិត្តិយស និងវង្សត្រកូល ដោយហេតុបន្ទាបខ្លួនទៅផ្តេកផ្តិតនិង នាងតាសីនេះឬ បាឯងធ្វើកេរ្តិ៍ឈ្មោះដ៏ល្អនៃបុព្វបុរសឲ្យសាបសូន្យទៅ នឹងនាំមកនូវសេចក្តីអប្បយស ដល់ខត្តិយវង្សដ៏ឧត្តមសក្តិ ដោយត្រូវ នាងតាសីពត់តាល់តែរេកខ្លួរ ការញញឹមញញែម ឬពោលកន្ទុយក្អែក

ជាសម្បត្តិរបស់ស្ត្រីអ្នកលេង   ចូរអ្នកត្រួតត្រាមើលឲ្យល្អ   កុំបីទុំស៊ុខមុខស្រគាល   កុំបីអាលគ្រុនមុខជម្ងឺ   រឿងនេះ ជាសេចក្តីអប្រិយ៍បំផុត មិនគួរប្រថុយប្រាណទៅផ្តេកផ្តិត សេចក្តីស្រឡាញ់រមែងមានពល់រូប អ្នកណាគេមិនឲ្យស្រឡាញ់ តែស្រឡាញ់ឲ្យគេប្បី   តែលោហិតប្រុសកម្លោះកំពុងពេញពាល   ច្រើនតែញ៉ាំងសេចក្តីវិកវរឲ្យកើតក្នុងចិត្ត ដោយមិនត្រិះត្រួតឲ្យសមគួរ   នេះជាហេតុឲ្យខូចសមានសក្តិនៃពជត្រកូល   និងជាមន្ទិលសៅហ្មងដល់គណ: ។

កិច្ចកតប:   ទូលបង្គំដឹងរឿងរ៉ាវអស់នេះសព្វគ្រប់អស់ហើយ   តែប្រហែលស្តេចបងនូវមិនទាន់ទ្រង់ជ្រាប   មរណកាលរបស់ទូលបង្គំក៏ចូលមកជិតណាស់មកហើយ   បើស្តេចបងមានបំណងឲ្យទូលបង្គំស្លាប់ ប្អូននឹងមើលចិត្តទូលបង្គំសោត   មិនចាំបាច់ស្តេចបងនាំយកបរមត្ថបរិយាមកទេសនាប្រកត្រចៀកមនុស្សដែលទៀបនឹងស្លាប់ដូចនេះទេ ។

ពនីត្រាស់   សេចក្តីបំណងរបស់បង   គឺជានឹងជួយប្អូនឲ្យផុតអំពីអប្បយសអាម៉ាស់មុខទាំងនេះជាប្រាកដ   តែបងតូចចិត្តណាស់ប្អូន   ដែលមកឃើញសណ្ហាប់ពាក្យជាស់តៀនរបស់បង   មានតែបក់ភ្លើងគឺសេចក្តីច្ឆន្ទតណ្ហារបស់អ្នកឯងឲ្យឆេះពេលពលខ្លាំងឡើង   ហាក់ដូចជាមកញុះប្អូនឯងឲ្យដើរទៅកាន់ផ្លូវវិនាសកម្ម   តែបើចេតនារបស់ប្អូនបំណងនឹងយកឲ្យបាន   ប្អូនឹងស្លាប់នោះ   បងជាបងនឹងឲ្យប្អូនស្លាប់ម្តេចបាន   ត្រូវតែ

ជ្រោមជ្រែងជួយជីវិតទុកសិន វៀរលែងតែរបស់ហួសវិស័យ ។

ត្រាស់ប៉ុណ្ណោះហើយ ព្រះទេពីក៏ចេញពីបន្ទប់នោះ មានសោវណី ឲ្យហៅនាងស្នំ សៃរិន្ធីៗ ចូលមកគាល់ ឈរចំពោះមុខព្រះទីនាំងចាំ ស្ដាប់ព្រះសោវណី កនី ឃើញនាងចូលមកគាល់ហើយ តែក៏មិនត្រាស់ ថាអ្វី ទ្រង់ប្រថាប់ព្រងើយ ដូចជាមានសេចក្ដីមួហ្មងអ្វីក្នុងព្រះហឫទ័យ មួយយ៉ាង តែដែលពិត ព្រះនាងកំពុងរិះគិតរកប្រយោគដែលនឹងត្រាស់ ចេញមក ព្រោះជារឿងសុខុម នឹងជារឿងមុខគួរខ្ពើម ព្រះនាងទើប ផ្ចង់រកផ្លូវមួយស្របក់សិន ទើបមានព្រះសោវណីថា មុខគួរស្ដាយ ណាស់ណោះ ដែលមកឃើញកន្យាអ្នកឧត្ដមសម្បូណ៌ដោយគុណសម្បត្តិ យ៉ាងនាងមកធ្លាក់ទៅជាទាសី សម្រាប់បម្រើការក្នុងផ្ទះដូចនេះ ។

សៃរិន្ធី តប នេះជាអកុសលកម្មរបស់ខ្ញុំម្ចាស់ វាតាមមកស្នង ផល ។

កនី ត្រាស់ យើងឃើញច្បាស់ថា នាងឯងមិនមែនជាស្ត្រីធម្មតា ព្រោះមានសរសៃក្រសៃលោហិតខៀវច្រើន ស្មើនឹងសរសៃលោហិត របស់យើង ល្អហើយ នាងគង់ត្រេកអរនៅកាលបានស្ដាប់ថា អនុជ របស់យើងមានសេចក្ដីស្នេហានាងឯង ហើយខ្លួនយើងក៏ពេញចិត្ត អ-នុជ ដែលបានឃើញនាងបាទបរិចារិការបស់អនុជ ។

ពាក្យនេះមិនធ្វើឲ្យ សៃរិន្ធី កើតត្រេកអរ ប្ដឹកអស្ចារ្យក្នុងចិត្ត

សោះឡើយ ត្រឡប់ជាធ្វើឲ្យនាងក្រេវក្រោធពេកដូចអគ្និត្រូវពាយុ ទើបតបព្រះរាជសោវណីថា វាអាម៉ាស់មុខណាស់ព្រះរាជិនី ម្ដេចព្រះម្ចាស់មិននឹកដល់រឿងនេះផង ខ្ញុំម្ចាស់មិនបានគិតមិនបាននឹកសោះឡើយថាព្រះម្ចាស់នឹងបន្ទាបព្រះអង្គ ចុះលេងក្នុងរឿងអប្រិយ៍នេះ ដែលអ្នកជាទាំងពួងគេមិនដែលនិយាយ ឬប្រព្រឹត្តមកសោះ ខ្ញុំម្ចាស់ទើបនឹងដឹងបានក្នុងវារៈនេះជាដំបូងថា សក្តិខ្ពស់នឹងកេរ្តិ៍ឈ្មោះល្អនោះ វាមិនបានជាប់នៅជាមួយគ្នាជានិច្ចទៅ ព្រះម្ចាស់ប្រហែលជាមិនដែលប្រទះឃើញនារីដែលសូលះជីវិតរបស់ខ្លួន ដើម្បីការពារកេរ្តិ៍កិត្តិយសទុក ប្រហែលជាទ្រង់ធ្លាប់ប្រទះតែស្ត្រីដែលឮតែសម្លេងប្រាក់ក្រើង ក៏ញញឹមដាក់ ហើយបណ្ដាលឲ្យប្រុសបានសម្រេចដូចប្រាថ្នា ខ្ញុំម្ចាស់គ្មានពាក្យអ្វីឡើយ ដែលនឹងក្រាបទូលឲ្យច្រើនទៅជាងនេះ មានតែពាក្យបញ្ចប់ពាក្យដើមបន្តិចទៀតថា អំពីនេះជាដើមទៅ ខ្ញុំម្ចាស់មិនបានជាសាវឡិក គាល់បម្រើព្រះម្ចាស់តទៅហើយ មានអំណាចនឹងបន់ទៅណាទៅបានតាមចិត្ត ។

រាណី ត្រាស់ជាប្រញាប់ថា កុំតូចចិត្តឡើយសាវឡិក ចូលឲ្យអភ័យដល់យើងចុះ ចូរភ្លេចពាក្យដែលយើងនិយាយអម្បាញ់ទៅ កុំខឹងស្រ-បាលឡើយ ចូរយកពែងស្រានេះទៅថ្វាយកិច្ចូក ម៉េះប្រហែលជាចាំមើលផ្លូវនាង ។

ពទី សម្គាល់ថា ដែលសៃរិន្ទ្រី សម្តែងអាការក្រៅក្រោធ និងជាមាយាស្រី ព្រោះនាងអស់សង្ស័យហើយ ជឿក្នុងព្រះហឫទ័យថា សៃរិន្ទ្រី គង់ត្រេកអរក្នុងរឿងដែលកិច្ចក មានចិត្តស្នេហាបដិព័ទ្ធនឹងខ្លួន ហើយជឿថា នាងគង់ត្រេកអរនឹងនាំពែងស្រាទៅថ្វាយកិច្ចក សៃរិន្ទ្រី ដឹងបានជាប្រាកដថា សុរាមួយពែងនេះ ជាឧបាយដើម្បីញ៉ាំងហេតុឲ្យសមផល ឲ្យអ្នកទាំងពីរគឺខ្លួននាងនិងកិច្ចកបានជួបគ្នាស្ងាត់ៗ ក្នុងជាន់ដំបូងនាងគិតរេក លុះគិតម្តងទៀតនាងក៏ព្រួយទៅ ដោយតាំងចិត្តខ្ជាប់ក្នុងកុសលកសី ជាកម្លាំងសម្រាប់តទល់អាការកំហែងបង្ខំដ៏ជ្រៅនៃបុរស នាងក៏ឱនតំនាប់ទទួលយកពែងសុរាអំពីព្រះហស្ត ពទី ក្នុងខណៈដែលនាងកំពុងដើរចូលទៅកាន់បន្ទប់កិច្ចកនោះ នាងនឹកក្នុងចិត្តថា វេលានេះយើងចូលទៅកាន់ទីជម្រុងជម្រះ ដូចចូលទៅក្នុងរូងនៃស្នេសត្វ យើងមិនដឹងបើនឹងប្រតិបត្តិដូចម្តេចឲ្យរួចខ្លួន បើយើងទទឹងអាជ្ញាពទីសោត ទោសទណ្ឌនឹងធ្លាក់លើខ្លួនយើង ឥឡូវនឹងប្រថុយទៅរកកិច្ចក សេចក្តីសៅហ្មងនឹងមានដល់ខ្លួនយើង ៗទីងគេបរទៅផ្លូវណាមិនរួចហើយ ប្រសិនបើយើងប្រតិបត្តិតាមបញ្ជាពទី អ្នកណានឹងដឹងបានថា ការចូលទៅក្នុងបន្ទប់ស្ងាត់តែពីរនាក់ ហើយគ្មានគ្រឿងការពារខ្លួនផង ពទីង មិនឲ្យទោសដល់ខ្លួនយើងម្តេចបាន អ្នកណានឹងធានាបានថា កិច្ចកនឹងមិនធ្វើអី រឿងនេះសូម្បីតែស្រីអ្នកព្រៃដែលស្លូតស្លុតចិត្តវិហោសម្បត្តិពក៌

គង់ខ្លាចច្រើនស្មើនឹងខ្លាចខ្លា តែពោះបីដូចមេ្ដចក៏ យើងទឹងព្យាយាម
ក្រោកកិត្តិយសរបស់យើងទុកដោយពេញកម្លាំង ដែលទឹងក្រោបាន ពោះ
បីបង់ជីវិតក៏តាមការ សូមព្រះជាម្ចាស់លើស្ថានសួគ៌ចូលជួយអភិបាលខ្ញុំ
ម្ចាស់ក្នុងគ្រានេះ ។

ដោយសេចក្តីគិតយ៉ាងនេះជាគ្រឿងឃុំចិត្ត នាងក៏ប្រថុយឈាន
ដើរចូលទៅកាន់បន្ទប់កិច្ចក ឯហេតុការណ៍ដែលកើតឡើងនោះ វាក៏
មិនខុសពីទីដែលនាងស្មានទុក កិច្ចកកាលឃើញនាងចូលទៅតែម្នាក់
ឯង ក៏ទឹកញញឹមប្រឹមប្រិយ៍ក្នុងចិត្ត ក្រោកឡើងស្ទុះទៅទងុបនាង ។ គ្មាន
សារ៉ុធទឹងការពារខ្លួនពិត តែនាងប្រឹងខ្លួនទុកតស៊ូដោយកម្លាំងកាយ នាង
ទះតបខ្ញាចខ្ញាំ ថ្ករបូតអំពីដៃកិច្ចក ដែលកំពុងស្រវឹងស្រា រត់ចេញអំពី
បន្ទប់ ។

ព្រះចៅក្រុងវិរាដវេលានោះ កំពុងប្រថាប់នៅក្នុងព្រះទីនាំងវិនិច្ឆ័យ
ខណៈនោះមានស្ត្រីម្នាក់ ស្រែករត់ចូលទៅមុខព្រះទីនាំង ចូលទៅដល់
បល្ល័ង្កគង់ ដោយអាការអាចហ៊ានទឹងស្រែកថា អយុត្តិធម៌ អយុត្តិធម៌
ដីហេមក កើតឡើងក្នុងមួយរាណាយុត្តិធម៌ហើយ ព្រះរាជាអើយកាលស្ត្រី
ភាពខ្ញុំមានកម្លាំងតិច គ្មានទីពឹងពាក់ មកត្រូវញាំញីសមានសេក្តីលេង
តាមអំពើចិត្ត ក្នុងខាងក្នុងកំផែង ៤ ជាន់នៃព្រះបរមមហារាជវាំងរបស់
ព្រះអង្គដូចនេះ សេចក្តីវិនាសសសៀរបួលដិតព្រះអង្គណាស់ហើយ ។

គ្រានោះមានមហាតលិកម្នាក់ ព្យាយាមបណ្តេញនាងចេញអំពីនោះ ហៅនាង មេចំគួន មកត្រើល និយាយត្រើល ៗ ខណៈនោះ កិច្ចកក៏តាមចូលមកក្នុងព្រះពេងគាល់ ចាប់សក់នាងដឹកយកទៅអំពីទីប្រជុំនោះ បណ្តាអ្នកប្រជុំអម្បាលនោះមិនទាន់ដឹងថា កើតហេតុរឿងអ្វីឡើយ កាលកិច្ចកអូសចូលទៅក្នុងវាំង សៃរិន្ធីបានស្រែកហៅផ្លូវសុំឲ្យប្រុសម្នាក់ឈរនៅជិតនោះជួយ ហើយមើលទៅដូចជាស្គាល់ប្រុសនោះផង តែខាងប្រុសនោះឃើញថាមិនគប្បីនឹងធ្វើអឹកធឹកកើតកណ្តាលផ្លូវថ្នល់ គ្រាន់តែខ្សិបប្រាប់នាងថា ឲ្យនាងធ្វើមាយានុទលំពេន ពុំមតាមគេទៅសិនទៅ ដល់វេលារាត្រីនឹងមានពួកមកជួយ មកនៅជិតៗនាង ដើម្បីនឹងជួយឲ្យរួចអំពីសេចក្តីអប្បយស ។

សៃរិន្ធី ក៏ប្រតិបត្តិតាម នាងស្ងៀមមិនមាត់ មួងអាការទទឹងតទៅ ដើរតាមកិច្ចក ចូលទៅក្នុងបន្ទប់ដោយស្រួល ក.បេតាំងពីរចូលទៅផុតហើយ កិច្ចកក៏ចាក់គន្លឹះទ្វារគ្រឹប ហើយពោលប្រលោមនាងថា កុំណាំ កុំកាត់មេត្រីក្តីស្នេហារបស់បងឡើង វង់ភក្ត្រដ៏ត្រឡង់ដូចរង់នៃខែមកបណ្តាលឲ្យបងវង្វេងស្មារតីទៅ ក្តីស្នេហាដ៏ធ្ងន់មហិមាស្មើមហាបរពត បានមកគ្របសង្កត់ហឫទ័យរបស់បង វេលានេះខ្លួនបងធ្លាក់ទៅជាទាសនៃសេចក្តីស្រឡាញ់ហើយ គ្មានអ្វីទឹងបន្ទបន្ទយទៀតទេ ក្រៅអំពីនាងព្រមព្រៀងទទួលបដិព័ទ្ធប៉ុណ្ណោះ កុំខឹងស្របាឡើយណាស្រស់ស្រី

បងសូមផ្ញើមេត្រីស្នេហាផង កុំឲ្យបងស្លាប់បង់អសោចអសារឥតការ ។

លំដាប់នោះ កិច្ចកខិតចូលជិតលាព្រះពាហា ជាទីបបួលឲ្យនាង នុប ហើយពោលមកទៀតថា សូមឲ្យបងនុបរិតថ្លឹតទ្រូងបង្ខិចស្រស់ស្រី ដើម្បីបន្ទោបង់នូវសេចក្ដីក្រហល់ក្រហាយ ដែលរុំរឹតចិត្តបង តអំពីនោះទៅ បងក៏ជារបស់នាង ។ ក៏ជារបស់បង ជានិរន្តរ៍ទៅណាពៅព្រលឹង ។

សៅរិន្ទីញញឹមដោយឧបាយ ហើយក៏ស្ងៀមនៅ មិនបានតបតសម្ដី កិច្ចកក៏និយាយប្រលោមតលួងទៅថា សេចក្ដីអៀនខ្មាសរបស់ញ [illegible]ដូចទឹកមុខយុវតីសៅរិន្ទី វាមកអុជកង់អគ្គីក្នុងទ្រូងបងឲ្យពេល ណា កុំខ្ចប់ចិត្ត ពន់ស្ងួចស្ងួនខែអំពីការសម្ងំរបស់រៀមឡើយ កុំស្ងាត់ស្ងៀមស្ងាត់ពេលក្រណោះសោកគ្នារ ចូរបង្ហាញមកតែមួយម៉ាត់ អំពីពាក្យស្នេហ៍ប្រៀបប្រដូចទុំមក្រោយ ក៏អាចនឹងជួយរំសាយទុក្ខនិងជ្រោមជ្រែងសាំងបងឲ្យគង់នៅបាន ។

ក្នុងទីបំផុតសៅរិន្ទីក៏ស្នងវាទីថា ៖ ម្ដេចទ្រង់ប្រញាប់ប្រញាល់ម៉្លេះ [illegible]ឲ្យយប់ឃោចសន្និយាសិន ខ្ញុំខ្មាសនឹងទៅណា ។

នាង ! អឺនបានដោយក្រណាស់ សម្រាប់ចិត្តអ្នកគួរស្រឡាញ់កំពុងពេញត្រូវរត់ខ្វល់ខណៈដង្ហើមបញ្ចូល ទឹងបង្អង់ចាំវេលានេះវេលានោះៗ និងប្រែថាម្ដេច កិច្ចក តបដោយសម្លេងញ័ររន្ទាន់ ។

សេចក្ដីខ្លាសក្នុងខណៈនោះពន់ពេក តែនាងក្លែងតែងខំព្យាយាមធ្វើមុខញញឹម ហើយឲ្យពាក្យបដិញ្ញាណថា នឹងមករកក្នុងវេលាព្រលប់យប់នេះមិនខាន សូមទានឲ្យតែបន្ធូរបន្ថយសិន ។

កិច្ចកនិយាយម្ដងទៀតក្នុងទីបំផុតថា បងគាប់ចិត្ត អំណរគុណជាបំផុត មធុរសកថាប៉ុណ្ណោះ អាចជួយរក្សាជួនចិត្តជីវិតបងឲ្យគង់នៅបានឃើញពន្លឺព្រះអាទិត្យតទៅ ខណៈនេះបងត្រឡប់ដឹងខ្លួនដូចកំណើតដើម ជីវិតរបស់បងប្រសិនជាមានប្រយោជន៍ដល់នាង សូមឲ្យតែបន្តិចបន្តួចក៏បងស៊ូលះឲ្យប្អូន ។

សម្រាប់ចិត្តខ្លួនស្រឡាញ់ ដែលកំពុងស្រឡាញ់ថ្មីៗ ក្ដៅៗ ឃើញថា វេ.លាដែលកន្លងទៅយឺតយូរជាបំផុត ចូលបែបតម្រាភាសិតថា កល់ៗ ម៉ោងដែលកន្លងទៅម្ដងៗនោះឃើញដូចជាយឺតយូរស្មើនឹងកាយុកាល បីដូចជាតា កង់រថព្រះអាទិត្យជាប់គាំងដូចនោះ ទោះបីដូចនេះក្ដី ពព្រើ កាលដែលកិច្ចកក្រវើនខ្លាន់ក្នុងចិត្ត ក៏បានមកដល់ក្នុងទីបំផុត វេលាសន្ធិយាចរមកដល់ មានស្រមោលងងឹតព្រិលងៀងទៅខាងខ្មៅ បានជួយឧបត្ថម្ភ ទឹកចិត្តកិច្ចកកំពុងដើរញាប់តិកៗ ឲ្យរីករាយឡើងបានបន្តិច ដោយមានសេចក្ដីសង្ឃឹមបង្កើតឡើង តែមកដល់ត្រង់នេះហើយៈឃើញនាឡិកា ហាក់ដូចជាដើរតែយឺតយូរជាងសព្វដង កិច្ចកដុំលើព្រះទែនប្រុងឥន្ទ្រីយ៍រវៀសរវៃ ចាំស្ដាប់សូរកើងនាងដោយលំអានទឹងឈានដើរចូលទៅរកខ្លួន ក្នុងទីបំផុតទ្វារបន្ទប់នោះ ក៏សន្សឹមៗបើកបន្តិចៗ រួប

ស្រស់បំព្រងតែងខ្លួនទងវែងដោយបានចូលទៅដល់ក្នុងបន្ទប់នោះ កិច្ចក ក្រឡេកឃើញញញឹមញញែមក្រោកឡើងអង្គុយ ហើយអញ្ជើញនាងឲ្យ អង្គុយក្នុងរង្វង់ដៃ នាងសន្សឹមៗ ដើរចូលទៅកាន់ទីព្រះទែន ដោះគ្រឿង តែងកាយជាន់ក្រៅចេញភ្លាម យីអើមិនមែនស្រីទេតើ កិច្ចកឃើញ ច្បាស់ទៅជាអ្នកចម្បាំងម្នាក់រូបសម្បើមមកឈរនៅមុខគេ ហើយស្រែក គំរាមថា អាខ្មោចឥតខ្មាស អាឯងមិនដឹងទេឬ ជាស្ត្រីបរិសុទ្ធមិនលក់ កិត្តិយសរបស់ខ្លួន ព្រោះឃើញលាភ ឥឡូវអាឯងចូលត្រៀមខ្លួនរើង ចិត្តខ្មៅរបស់អាឯង ដើម្បីចុះទៅកាន់នរកភូមិជាឆាប់ ។

និយាយតែប៉ុណ្ណោះ គេក៏ចាប់កិច្ចកកន្ត្រាក់អំពីព្រះទែនប្រហារជីវិត ដោយក្ដាប់ដៃដ៏មានឫទ្ធិស្លាប់បង់ ភីម អ្នកក្លែងខ្លួនជាស្ត្រី ក៏ប្រវាឡើង កំផែងវាំងកិច្ចក ចុះទៅដេកព្រងើយ គ្មានអ្នកឯណាទីមួយក្នុងវាំងនោះ ដឹង ថាមានហេតុកើតឡើង ។

ព្រឹកឡើងទាល់តែថ្ងៃហួស បន្ទប់ទំបន្ទំកិច្ចកនៅតែបិទ អ្នកទាំង ពួងសង្ស័យ មាន ទទួលសវនិយទៅពិនិត្យមើល ដើម្បីឲ្យដឹងជា ហេតុដូចម្ដេច លបើកទ្វារចូលទៅ អ្នកបម្រើនោះក៏ទប់ង៉ក់ធ្វើក្អកក្រ ល្វង ព្រោះឃើញសពកិច្ចកដេកស្តូក លោហិតប្រលាលពាសទាំងល្វែង និងប្រឡាក់ទៅតាមខ្លួនសព កាលសេចក្តីនោះជ្រាបទៅដល់ព្រះញាតិវង្ស ក៏ភ្ញាក់ផ្អើលតែពល់គ្នា រាទីជាព្រះជេដ្ឋភគិនី ក៏ទៅជាខ្យល់ចាប់បាត់ ស្មារតី ដោយអំណាចទោសឃោរឃៅ អ្នកអម្បាលនោះក៏រករឿងចោទ

ថា នាងពាសីជាអ្នកសម្លាប់ តែមិនមានស្នាមបន្ទាល់ល្មមយកជាការពិត បានព្រោះមានសេចក្ដីឃើញថា រឿងឃាតកម្ម ប្រុសមានប្រាណមាំមួន យ៉ាងកិច្ចកនេះ ស្ត្រីមិនអាចនឹងធ្វើបាន ទោះបីដូចនោះក្ដី មនុស្សទាំងឡាយក៏មិនអស់សង្ស័យ នូវមានសេចក្ដីឃើញថារឿងឃាតកម្មគ្រានេះ ជាករណីហេតុស្មាគកំបាំង តែកទីទ្រង់សង្ស័យ ត្រង់ដែលថា សៃរិន្ទ្រី ជាអ្នកដើមហេតុ ដោយហេតុនេះព្រះនាងមិនបានបិទបាំងរឿងសង្កានេះ ទុក តែងត្រាស់ប៉ោច ១ ជាញយ១ ថាតែឃើញមុខនាងពាសីកាលណា ឲ្យនឹកដិនទឹកស៊ីក្នុងចិត្ត ព្រោះតែឃើញហើយ បណ្ដាលនឿនព្រះហឫទ័យឲ្យព្រះនាងនឹកដល់មរណកម្មរបស់ព្រះអនុជ ក្នុងទីបំផុតព្រះរាជា ក៏ត្រូវខ្យល់ខ្លួចត្រឡប់ត្រឡិននាំឲ្យជឿពាក្យព្រះមហេសី ត្រាស់ឲ្យបងដៃបង់ជើងសៃរិន្ទ្រី នាំយកទៅដុតទាំងរស់ ព្រមនឹងសពកិច្ចកលើជើងថ្ករជាមួយគ្នា ។

ឯនាងពាសីសៃរិន្ទ្រី ត្រូវគេផ្ដាញ់ផ្ដាលជាច្រើនហ៊ាង ដើម្បីនឹងឲ្យនាងទទួលសារភាពតាមពិត តែនាងខំអត់ធន់ទារុណកម្មនោះ ដោយសេចក្ដីមានឧក្កាហាន ដោយឈ្មោងយល់ច្បាស់ថា ពួកបាណ្ឌវក្សត្រិយ៍នឹងមកជួយនាងឲ្យរួចអំពីភ័យក្នុងវេលាមានឱកាស ការដែលត្រូវបង់ដៃបង់ជើងតែក្រញុះ ដូចជាគេបង់ជ្រូកនោះ មិនធ្វើឲ្យរាទីមានសេចក្ដីសង្វេគវេទនាសោះ ព្រោះក្នុងវេលានោះ ព្រះនាងពេញទៅដោយសេចក្ដី

ទុក្ខសោក នឹកស្រណោះស្តាយព្រះអនុជដែលសុគតទៅ និងដិតចិត្តនឹងនាងទាសីជាទម្ងន់ ។

លំដាប់នោះ គេនាំនាងទៅកាន់សុសានប្រទេស(១) មានទាហានប្រមាណ ៥០ នាក់ឃុំខ្លួននាងទៅ ដើម្បីការពារមិនឲ្យនាងរត់ និងចាំការពារមិនឲ្យពួកញាតិរបស់នាងមកដណ្តើមយកខ្លួននាងទៅបាន ។

ទីមេន(២) នោះគេបានចាត់ចែងតម្កល់ជើងថ្ករ ត្រៀមទុកថ្វាយព្រះភ្លើងសពកិច្ចក ចំណែកឯនាងក៏ត្រូវបង្គាប់ឲ្យឡើងទៅដុតខ្លួនសម្លាប់លើជើងថ្ករនេះ ព្រមនឹងសពកិច្ចកដែលគេចោទថានាងជាអ្នកសម្លាប់ តែមុននឹងឡើងទៅលើជើងថ្ករ គេបានអនុញ្ញាតឲ្យនាងប្រកាសតិសេចក្តីឯណាទីមួយ មុនវេលាលាស្លាប់ ថាបើនាងមានបំណងនឹងពោលបច្ឆិមវាចា លំដាប់នោះនាងក្រោកឡើងឈរដោយអាចហាន ហើយនិយាយសម្តែងយ៉ាងច្បាស់លាស់ មិនមានរន្ធត់ថា :

ម្នាលសុភាពបុរសទាំងឡាយ ប្រសិនជាអ្នកមកនឹកមួយរំពេចមើលថា បើមាតា បងស្រី ប្អូនស្រី បុត្រី របស់អ្នក បាននូវសេចក្តីអាម៉ាស់មុខ ព្រោះប្រុសដែលស្លាប់ទៅនេះ ទាំងនាងនោះឯងក៏មិនពេញចិត្តនឹងយកសម្ភានសក្តិរបស់ខ្លួនមកប្តូរនឹងប្រុសនេះ ដូចយ៉ាងខ្ញុំនេះ តើអ្នកនឹងចងដៃចងជើងយកនាងទៅដុតទាំងរស់ ព្រោះហេតុដែលនាងព្យាយាមនឹងការពារសេចក្តីបរិសុទ្ធរបស់នាងឬ ខ្ញុំជឿថា អ្នកទាំងពួងគង

១- ទីដុតខ្មោច ។ ២- មេន គឺមេរុ ។

នឹងប្រកែកព្រមគ្នាថា នឹងមិនធ្វើដល់នាងឡើយ ថាបើដូចនោះសោត ហេតុម្តេចស្ត្រីកំសត់គ្មានផ្ទះសម្បែង គ្មានញាតិវង្ស គ្មានអ្វីបរិភោគចិញ្ចឹមជីវិត រស់នៅដោយត្រដរ ដោយអ្នកដទៃឲ្យទាន មកត្រូវទោសដូចនេះ ខុសនឹងអ្នកទាំងពួង ក្នុងមួយវេលាឬពីរបីមីនុតទៀត ខ្ញុំនឹងផុតជីវិតគ្មានខ្លួន តែចិត្តរបស់ខ្ញុំនឹងត្រាច់ទៅក្នុងលោក ចិត្តរបស់ព្រហ្មចារិនីមិនចេះស្លាប់ ។

លុះនាងនិយាយចប់ចុះផុតមាត់ ឃើញបុរសម្នាក់ខ្មៅធំមាំរត់សំដៅទៅមាត់ទន្លេ ត្រង់ទីដែលនឹងថ្វាយព្រះភ្លើងសព កិច្ចក ស្រែកបណ្តើរថា ខ្លួនគេកាន់រាជសារមក ដោយមានកិច្ចដ៏ប្រញាប់ គេរត់ចូលមកយ៉ាងលឿនៗ ទាល់តែអ្នកក្រឡាការនឹងហាមឃាត់ ឬសួរយកសេចក្តីមិនទាន់ៗ ដឹងជាអ្នកនោះមកល្អ ឬមកអាក្រក់ គេក៏ដល់មកទីប្រជុំជន រត់កាត់ហ្វូងអ្នកក្រឡាការដែលឈរត្រៀបជុំវិញ ក្រប៊ីដែលកាន់នៅដៃក៏វាត់ឆ្វេងវាត់ស្តាំ ត្រូវដាច់ករធ្លាក់អំពីកាយរណាល ហើយស្រែកប្រកាសដោយសម្លេងដ៏ខ្លាំងថា ៖

កិច្ចរបស់យើងដែលមកនាំងប្រញាប់ប្រញាល់នេះ ក៏គឺទាន់មកជួយស្ត្រីដែលជាប់ចំណងនេះ កិច្ចតទៀត គឺនឹងសម្តែងឲ្យមនុស្សទាំងឡាយឃើញថា ដែកតូចមុខមុតនេះ (យកដៃចង្អុលទៅក្រប៊ី) នឹងប្រហារក្បាលអ្នកកល់គ្នាឲ្យកំបុតទៅបាន ។

និយាយដូចនោះហើយ គេក៏ស្ទុះប្រវាឡើងទៅលើជើងថ្ករទៅជួយ

ស្រាយសែរីន្ទរិ ហើយទាំចុះមក វេលាត្រឡប់មក បានកាប់សម្លាប់គ្នានឹងពួកអ្នករក្សាការ ១ ក្លេងធំ គេកាត់ឆ្វេងក្របែលស្ដាំដោយក្របីសម្រាប់ដៃខ្លះ សាច់ដៃខ្លះ ដាច់ជើងស្លាប់ទៅប្រមាណ ២០ នាក់ ឈាមបាចប្រសាចពាសមាត់ទន្លេ ទីឈាបនកិច្ចក្លាយទៅជាទីចម្បាំង ពេញទៅដោយលោហិតមនុស្ស អ្នករស់រួចជីវិតទៅក៏មិនប៉ុន្មាននាក់ អ្នកដែលរួចអំពីមុខក្របី ក៏គឺអ្នកដែលគេចរត់ទៅជាមុន ស្រេចការកាប់សត្រូវដោយកម្លាំងក្លាមុខគួរព្រឺព្រួចប៉ុណ្ណោះហើយ បុរសនោះក៏ត្រកងសែរិន្ទរីដាក់លើស្នាលីរហិចយាត្រាទៅ ក្នុងរយៈផ្លូវឆ្ងាយផុតកន្ទុយភ្នែក ។

(មានតទៅទៀត)